ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៤ លេខ ១៥ ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍

មាតិកា

I .ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៣–៤–១៩៩៦– ព្រះរាជក្រឹត្យ ជស/រកត/០៤/៩៦/១២ ៦៤០

០៨–៤–១៩៩៦– ព្រះរាជក្រឹត្យ នស/រកត/០៤៩៦/២៥ បង្កើតអាជ្ញាធរជាតិមួយសំរាប់ទទួលបន្ទុកដោះស្រាយកិច្ចការព្រំដែន ហៅកាត់ «អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន» ៦៤១

០៨–៤–១៩៩៦– ព្រះរាជក្រឹត្យ នស/រកត/០៤៩៦/២៦ តែងតាំងឯកឧត្តម **ញឹម វណ្ណដា** ជាឧកញ៉ា ៦៤៦

០៨–៤–១៩៩៦– ព្រះរាជក្រឹត្យ នស/រកត/០៤៩៦/២៧ តែងតាំងលោក **ម៉ុង ឫទ្ធី** ជាឧកញ៉ា ៦៤៧

១៧–៤–១៩៩៦– ព្រះរាជក្រឹត្យលេខ នស/រកត/ ០៤៩៦/២៨ បន្ថយរយៈពេលរងទោសឱយទណ្ឌិត ៦៤៨

II - ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

១៩–៤–១៩៩៦– អនុក្រឹត្យលេខ ១៤ អនក្រ.បក ស្តីពីការបែងចែកខ្ទង់ចំណាយឥតគ្រោងទុក ៦៥៥

១៧–៤–១៩៩៦– អនុក្រឹត្យលេខ ៦១ អនក្រ.ត.ត ស្តីពីការកែសំរួលឋានន្តរសក្តិនាយទាហាន ៦៥៦

១៨-៤-១៩៩៦- អនុក្រឹត្យលេខ ៦២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៥៧
១៨-៤-១៩៩៦- អនុក្រឹត្យលេខ ៦៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៥៨
១៨-៤-១៩៩៦- អនុក្រឹត្យលេខ ៦៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៥៩
១៨-៤-១៩៩៦- អនុក្រឹត្យលេខ ៦៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៦០
១៨-៤-១៩៩៦- អនុក្រឹត្យលេខ ៦៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៦១
២២-៤-១៩៩៦- អនុក្រឹត្យលេខ ៦៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៦៦២
២៣-៤-១៩៩៦- អនុក្រឹត្យលេខ ៦៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៦៦៤

២ - សេចក្ដីសំរេច

១៨-៤-១៩៩៦- សេចក្ដីសំរេចលេខ ១២ សសរ ស្ដីពីការប្រគល់ភារកិច្ចបណ្ដោះអាសន្ន ៦៦៥

III - ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

១៨-៤-១៩៩៦- ប្រកាសលេខ ៣១២ ថព.ប្រក អនុញ្ញាតអោយលោក នៅ សុខា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីនចំនួន ០២ គ្រឿង ៦៦៦
១៨-៤-១៩៩៦- ប្រកាសលេខ ៣១២ ថព.ប្រក អនុញ្ញាតអោយលោក នៅ សុខា ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើររោងម៉ាស៊ីនបំរុងផលិត

ថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីនចំនួន ០៣ គ្រឿង ៦៦៧

១៨-៤-១៩៩៦- ប្រកាសលេខ ៣១២ ថព.ប្រក អនុញ្ញាអោយលោក **ទ៊ាន់ភាម៉ុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីនចំនួន ០២ គ្រឿង ៦៦៨

១៨-៤-១៩៩៦- ប្រកាសលេខ ៣១២ ថព.ប្រក អនុញ្ញាអោយលោក **ស៊ឿ ផល្លា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការ រោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីន ០១ គ្រឿង ៦៦៩

១៨-៤-១៩៩៦- ប្រកាសលេខ ៣១២ ថព.ប្រក អនុញ្ញាអោយលោក **ហេង សាង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីន ០១ គ្រឿង ៦៧០

១៨-៤-១៩៩៦- ប្រកាសលេខ ៣១២ ថព.ប្រក អនុញ្ញាតអោយលោក **ហេង តែ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីន ចំនួន ០២ គ្រឿង ៦៧០

១៨-៤-១៩៩៦- ប្រកាសលេខ ៣១២ ថព.ប្រក អនុញ្ញាតអោយលោក **អ៊ុន សុផល** ជនជាតិខ្មែរសញ្ជាតិកម្ពុជា បន្តដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីន ចំនួន ០២ គ្រឿង ៦៧១

១៨-៤-១៩៩៦- ប្រកាសលេខ ៣១២ ថព.ប្រក អនុញ្ញាតអោយលោក **ឡេង គីមហ្លួយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីន ចំនួន ០១ គ្រឿង ៦៧២

១៨-៤-១៩៩៦- ប្រកាសលេខ ៣១២ ថព.ប្រក អនុញ្ញាតអោយលោក **ជាម តាយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីន ចំនួន ០១ គ្រឿង ៦៧៣

១៨-៤-១៩៩៦- ប្រកាសលេខ ៣១២ ថព.ប្រក អនុញ្ញាតអោយលោក **ហែម វណ្ណសឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា បើកដំណើរការ

ឃ

រោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីនចំនួន ០២ គ្រឿង ៦៧៤

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

១៨-៤-១៩៩៦- ប្រកាសលេខ ៣២៧ អយក.ប្រក ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យ ព្រែកអំបិល ទៅជា «អនុវិទ្យាល័យ **ហ៊ុន សែន** ព្រែកអំបិល» ក្នុងស្រុកស្អាង ខេត្តកណ្តាល ៦៧៥

១៨-៤-១៩៩៦- ប្រកាសលេខ ៣២៨ អយក.ប្រក ស្តីពីការបើក «អនុវិទ្យាល័យ **ហ៊ុន សែន** គ្រប់» ក្នុងស្រុកបាធាយ ខេត្តកំពង់ចាម ៦៧៦

១៨-៤-១៩៩៦- ប្រកាសលេខ ៣២៩ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យ តាកែវ ទៅជា «វិទ្យាល័យ **ជា ស៊ីម** តាកែវ» ក្នុងខេត្តតាកែវ ៦៧៨

១៩-៤-១៩៩៦- ប្រកាសលេខ ៣៣០ អយក.ប្រក ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា **ចំន្ទ សារុន** ស្មៅខ្ចី ៦៧៩

I - ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ ជស/រកត/០៤/៩៦/១២

យើងព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តមធម្មិក មហារាជាធិរាជ បរមនាថ

បរមបពិត្រ ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៦

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង :

- ឯកឧត្តម **សោម ចំនួរឹម** ជា អគ្គាធិការ
- ឯកឧត្តម **ឡី ម៉េង** ជា អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស
- ឯកឧត្តម **សួស គង់** ជា អគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល ហិរញ្ញកិច្ចនិងផែនការ នៃក្រសួងអភិវឌ្ឍន៍ជនបទ ។

មាត្រា ២ : នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

* * *

ព្រះរាជក្រឹត្យ នស/រកត/០៤៩៦/២៥

យើងព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង

កម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលជាតិកម្ពុជា
- តាមសេចក្តីស្នើរបស់សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ :

ទ្រង់ត្រាសសំរេច :

មាត្រា ១ : បង្កើតអាជ្ញាធរជាតិមួយសំរាប់ទទួលបន្ទុកដោះស្រាយកិច្ចការព្រំដែនហៅថា «អាជ្ញាធរ ជាតិទទួលបន្ទុកកិច្ចការព្រំដែន » ដែលមានសមាសភាពដូចតទៅ :

១-សម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១

២–សម្តេច នាយករដ្ឋមន្ត្រីទី២ សហប្រធាន

៣–សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុប្រធាន

៤–រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៥–ឯកឧត្តម **ឌិត មុន្ទី** អតីតប្រធានគណៈកម្មាធិការព្រំដែន ទីប្រឹក្សាប្រចាំអាជ្ញាធរ

៦–សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៧–រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៨–សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សមាជិក

៩–អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក

១០–ឯកឧត្តម **វ៉ា គីមហុង** ទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយក រដ្ឋមន្ត្រីទី២ ទទួលបន្ទុកការងារព្រំដែនឋានៈស្មើរដ្ឋលេខាធិការ សមាជិកអចិន្ត្រៃយ៍

១១–ឯកឧត្តម **ឡុង វិសាលោ** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី២ សមាជិក

១២–ប្រធាននាយកដ្ឋានភូមិសាស្ត្រ អគ្គលេខាធិការ

មាត្រា ២ : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានភារកិច្ច ÷

– រៀបចំ និងកសាងលិខិតបទដ្ឋានមានលក្ខណៈច្បាប់ស្តីពីការកំណត់ព្រំដែនដីគោក និង ព្រំដែនសមុទ្រ ដើម្បីយកទៅតំកល់នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។

–ស្រាវជ្រាវនិងសិក្សាអោយបានហ្មត់ចត់បំផុត ក្នុងការជ្រើសរើសយកផែនទីលំនាំណាមួយសំរាប់ធ្វើការកំណត់បន្ទាត់ព្រំដែនដីគោកនិងព្រំដែនសមុទ្រអោយបានច្បាស់លាស់ រវាងព្រះ រាជាណាចក្រកម្ពុជា ជាមួយបណ្តាប្រទេសជិតខាង ។

–ធ្វើការចរចា សំរបសំរួល ដោះស្រាយ និងសំរេចលើបញ្ហាព្រំដែនជាមួយបណ្តាប្រទេសជិតខាងលើរាល់កិច្ចការដែលមានទំនាក់ទំនងលើការងារព្រំដែន ក្រោយពីមានការឯកភាពពីគណៈរដ្ឋមន្ត្រី ។

–សហប្រធានមានសិទ្ធិចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីបញ្ហាព្រំដែន ក្នុងនាមអាជ្ញាធរទទួលបន្ទុកកិច្ចការព្រំដែន ។

មាត្រា ៣ : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានយន្តការ ២ ជាលេខាធិការ :

យន្តការទី១ :ជាគណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែន(Task Force sur létude juridique)សមាសភាពនិងភារកិច្ចនៃគណៈកម្មាធិការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

យន្តការទី២:ជាគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន (Task Force Technique) ។ សមាសភាពនិងភារកិច្ចនៃគណៈកម្មាធិការនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៤ : យន្តការទាំងពីរនេះមានលេខាធិការដ្ឋានរួមមួយអចិន្ត្រៃយ៍ នៅនាយកដ្ឋានភូមិសាស្ត្រនៃទីស្តីការគណៈរដ្ឋមន្ត្រី ហៅថា : លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនដែលមាន ÷

- ឯកឧត្តម **វ៉ា គឹមហុង** ជាសមាជិកអចិន្ត្រៃយ៍អាជ្ញាធរទទួលបន្ទុកលេខាធិការដ្ឋាន
- ឯកឧត្តម **ម្ប្រាស់ លាស់** ជាជំនួយការទទួលបន្ទុកលេខាធិការដ្ឋាន
- ប្រធាននាយកដ្ឋានភូមិសាស្ត្រ អគ្គលេខាធិការអាជ្ញាធរ ជាប្រធានលេខាធិការដ្ឋាន
- ប្រធាននាយកដ្ឋានសូរិយោដី អនុប្រធានលេខាធិការដ្ឋាន
- លេខាធិការនៃគណៈកម្មាធិការនីតិកម្ម ស្តីពីកិច្ចការព្រំដែន ជាសមាជិក
- លេខាធិការនៃគណៈកម្មាធិការបច្ចេកទេស ស្តីពីកិច្ចការព្រំដែន ជាសមាជិក
- មន្ត្រីជំនាញការមួយចំនួន តាមសេចក្តីត្រូវការជាក់ស្តែង

លេខាធិការដ្ឋាននេះ ជាអ្នកសំរបសំរួលកិច្ចការ រវាងគណៈកម្មាធិការនីតិកម្មស្តីពីកិច្ចការព្រំដែន និងគណៈកម្មាធិការបច្ចេកទេសស្តីពីកិច្ចការព្រំដែន ហើយជាក្បាលម៉ាស៊ីនរដ្ឋបាល និងជាហិរញ្ញកិច្ចរបស់អាជ្ញាធរ ជាតិទទួលបន្ទុកកិច្ចការព្រំដែន ដោយប្រើប្រាស់មន្ត្រីរបស់នាយកដ្ឋានភូមិសាស្ត្រ នាយកដ្ឋានសូរិយោដី មន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ និងមន្ត្រីនៃលេខាធិការដ្ឋានរបស់យន្តការទាំង២ សំរាប់ជំនួយការ ។ លេខាធិការដ្ឋាន អចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ទទួលបន្ទុកកសាងផែនការ ចំណាយរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

មាត្រា ៥ : លេខាធិការដ្ឋាន មានភារកិច្ច ÷

-សិក្សាស្រាវជ្រាវនិងស្វែងយល់បន្ថែមលើការងារបច្ចេកទេស ដែលពាក់ព័ន្ធទៅ នឹងបញ្ហាព្រំដែនដើម្បីរៀបចំ និង កសាងដោយផ្ទាល់អោយបានលិខិតបទដ្ឋានមានលក្ខណៈច្បាប់ សំរាប់យកទៅដាក់ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

-ចុះពិនិត្យនិងធ្វើការវាស់វែងដល់ទីកន្លែងកើតហេតុនានាតាមបណ្តោយព្រំដែន រួចរាយការណ៍ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីពិនិត្យ និង សំរេច ។

-ចូលរួមចរចាជាមួយប្រទេសជិតខាង ដើម្បីកំណត់ជ្រើសរើសយកផែនទីសំរាប់ធ្វើជាមូលដ្ឋានក្នុងការដោះស្រាយបញ្ហាបច្ចេកទេសអោយបានត្រឹមត្រូវច្បាស់លាស់ ។

-សហការជាមួយអភិបាល ឬ អភិបាលរងខេត្ត ក្រុងដែលនៅជាប់ព្រំដែនជាមួយប្រទេសជិតខាងក្នុងការសិក្សាស្រាវជ្រាវលើទីតាំងព្រំដែន សីមា ជាក់ស្តែងទៅនឹងបញ្ហាបច្ចេកទេសជំនាញ រួចរាយការណ៍អំពីលទ្ធផល ជូនអាជ្ញាធរទទួលបន្ទុកកិច្ចការព្រំដែន ។

-ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយនិងការកំណត់ព្រំដែនជាមួយប្រទេសជិតខាង ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនសំរាប់រាយការណ៍ ថ្វាយនិងជូនគណៈរដ្ឋមន្ត្រី ។

មាត្រា ៦ : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រីសំរាប់សំរួលការងារ ។

សមាជិកអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធាន ។

មាត្រា ៧ : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនមានខ្ទង់ថវិកាដោយឡែក សំរាប់ចំណាយដោយផ្ទាល់ក្នុងការងាររបស់ខ្លួន នៅទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៨ : សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ សម្តេចនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលជាតិកម្ពុជា រដ្ឋមន្ត្រីពាក់ព័ន្ធ រដ្ឋមន្ត្រីនិងអគ្គភាពសាមី និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជ ក្រឹត្យនេះ ។

មាត្រា ៩ : ព្រះរាជក្រឹត្យនេះចូលជាធរមានច្បាប់ចាប់ពីថ្ងៃឡាយព្រះរាជហស្តលេខានេះតទៅ

ហើយ ជំនួសអោយព្រះរាជក្រឹត្យលេខ នសរកត ០២៩៥-១៩ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ដែលត្រូវទុកជានិរាករណ៍ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

ព្រះរាជក្រឹត្យ នស/រកត/០៤៩៦/២៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

ឯកឧត្តម ញ៉ឹម វណ្ណដា

ជា

ឧកញ៉ា

រាជធានីភ្នំពេញ . ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៤៩៦/២៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ម៉ុង ឫទ្ធី

ជា

ឧកញ៉ា

រាជធានីភ្នំពេញ , ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ១៩៩៦

ព្រះហស្ថលេខា

នរោត្តម សីហនុ

* * *

ព្រះរាជក្រឹត្យ នស/រកត/០៤៩៦/២៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០.៦.៨៨

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ថយរយៈពេលរងទោសចំនួន ១២ ខែ អោយទណ្ឌិត ៥ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយនាមខាងក្រោម :

១- ទណ្ឌិតឈ្មោះ **ឆន់ ហន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាម អំណាចសាលក្រមលេខ ១ ចុះថ្ងៃទី ០២-៤-៨៣ របស់តុលាការខេត្តកណ្តាល ។

២- ទណ្ឌិតឈ្មោះ **និត លី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២ ចុះថ្ងៃទី ២៣-៦-៨៧ របស់តុលាការខេត្តកណ្តាល ។

៣- ទណ្ឌិតឈ្មោះ **ស្រួយ ស្រ៊ន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ អស់មួយជីវិត តាមអំណាចសាលក្រមលេខ ១ ចុះថ្ងៃទី ២៦-៥-៨៣ របស់តុលាការក្រុងភ្នំពេញ ។

៤- ទណ្ឌិតឈ្មោះ **លឹម សុចិត្ត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ ចុះថ្ងៃទី ២៩-៤-៨២ របស់តុលាការក្រុងភ្នំពេញ ។

៥– ទណ្ឌិតឈ្មោះ **សួន សារឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលាក្រមលេខ ៨ ចុះថ្ងៃទី ៨–៩–៨៦ របស់តុលាការខេត្តកណ្តាល ។

មាត្រា ២ : ត្រូវបន្ថយរយៈពេលរងទោសចំនួន ៩ ខែ អោយទណ្ឌិតចំនួន ៧ នាក់ ដែលបានខិតខំអប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយនាមខាងក្រោម :

១– ទណ្ឌិតឈ្មោះ **សោម គ្រឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលាក្រមលេខ ៥ ចុះថ្ងៃទី ១៧–៨–៩៣ របស់តុលាការខេត្តក្រចេះ ។

២– ទណ្ឌិតឈ្មោះ **ពូន ជយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលាក្រមលេខ ៥ ចុះថ្ងៃទី ៦–៥–៩៣ របស់តុលាការខេត្តកណ្តាល ។

៣– ទណ្ឌិតឈ្មោះ **ម៉ៃ ដា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលាក្រមលេខ ៦៤ ចុះថ្ងៃទី ២៤–១២–៩៣ របស់តុលាការខេត្តកណ្តាល ។

៤– ទណ្ឌិតឈ្មោះ **ម៉ិុយ សុខ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលាក្រមលេខ ៦៦ ចុះថ្ងៃទី ២៨–១២–៩៣ របស់តុលាការខេត្តកណ្តាល ។

៥– ទណ្ឌិតឈ្មោះ **ឆាំង មុំ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលាក្រមលេខ ៧ ចុះថ្ងៃទី ១៤–៥–៩៣ របស់តុលាការ ខេត្តកណ្តាល ។

៦– ទណ្ឌិតឈ្មោះ **ឡាច ឈិត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលាក្រមលេខ ៥២ ចុះថ្ងៃទី ៣–៣–៩៤ របស់តុលាការខេត្តកណ្តាល ។

៧– ទណ្ឌិតឈ្មោះ **កន គីម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលាក្រមលេខ ៣៦ ចុះថ្ងៃទី ២០–៨–៩៣ របស់តុលាការខេត្តកណ្តាល ។

មាត្រា ៣ : ត្រូវបន្ថយរយៈពេលរងទោសចំនួន ៦ ខែ អោយទណ្ឌិតចំនួន ១៦នាក់ ដែលបាន ខិតខំ អប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយនាមខាងក្រោម :

១- ទណ្ឌិតឈ្មោះ **ឃឹម នី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី ២៤.៣.៩៥ របស់តុលាការខេត្ត ក្រចេះ ។

២-ទណ្ឌិតឈ្មោះ **ញ៉េរញ៉ូ ម៉ាប់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ២ ចុះថ្ងៃទី ២៣.៣.៩៥ របស់តុលាការ ខេត្តក្រចេះ ។

៣-ទណ្ឌិតឈ្មោះ **យុទ្ធ មោច** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាម អំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ២៣.៣.៩៥ របស់តុលាការ ខេត្តក្រចេះ ។

៤-ទណ្ឌិតឈ្មោះ **សេច សេង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាម អំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ២៣.៣.៩៥ របស់តុលាការ ខេត្តក្រចេះ ។

៥-ទណ្ឌិតឈ្មោះ **ឈាង ឡេញ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាម អំណាចសាលក្រមលេខ ២១ ចុះថ្ងៃទី ២៩.៦.៩៣ របស់តុលាការ ខេត្តកណ្តាល ។

៦- ទណ្ឌិតឈ្មោះ **ហែម ខាន់** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤០ ចុះថ្ងៃទី ២១.២.៩៤ របស់តុលាការ ខេត្តកណ្តាល ។

៧- ទណ្ឌិតឈ្មោះ **សឿន សុខឡេង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៨ ចុះថ្ងៃទី ១២.៥.៩៤ របស់ តុលាការខេត្តកណ្តាល ។

៨- ទណ្ឌិតឈ្មោះ **ម៉ៃ សុផល** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៦ ចុះថ្ងៃទី ១៩.១១.៩៣ របស់តុលាការ ខេត្ត កណ្តាល ។

៩– ទណ្ឌិតឈ្មោះ **ឆន យ៉ាត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាម អំណាចសាលក្រមលេខ ១១៩ ចុះថ្ងៃទី ១៧.៥.៨៤ របស់តុលាការខេត្ត កណ្តាល ។

១០– ទណ្ឌិតឈ្មោះ **អ៊ុម ហ៊ី** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាម អំណាចសាលក្រមលេខ ១១៤ ចុះថ្ងៃទី ១៤.៥.៨៤ របស់តុលាការខេត្ត កណ្តាល ។

១១– ទណ្ឌិតឈ្មោះ **គង់ គឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២២ ចុះថ្ងៃទី ២០.៥.៨៤ របស់តុលាការ ខេត្តកណ្តាល ។

១២– ទណ្ឌិតឈ្មោះ **សឿង ឡេក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២២ ចុះថ្ងៃទី ២០.៥.៨៤ របស់ តុលាការខេត្តកណ្តាល ។

១៣– ទណ្ឌិតឈ្មោះ **នួច គឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២២ ចុះថ្ងៃទី ២០.៥.៨៤ របស់តុលាការ ខេត្តកណ្តាល ។

១៤– ទណ្ឌិតឈ្មោះ **យឹម សុផុន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៤ ចុះថ្ងៃទី ២១.៣.៨៤ របស់ តុលាការខេត្តកណ្តាល ។

១៥– ទណ្ឌិតឈ្មោះ **ដាំង អាន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៩៨ ចុះថ្ងៃទី ៥.៥.៨៤ របស់តុលាការខេត្ត កណ្តាល ។

១៦– ទណ្ឌិតឈ្មោះ **ឈាន សុធា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៦១ ចុះថ្ងៃទី ១៦.៥.៨៤ របស់តុលាការ ក្រុងភ្នំពេញ ។

មាត្រា ៤ : ត្រូវលើកលែងទោសអោយទណ្ឌិតចំនួន ២០ នាក់ ដែលបានខិតខំរះប់រកែប្រែខ្លួន បានល្អ ក្នុងរយៈពេលទទួលរងទោសកន្លងមកដូចមានរាយនាមខាងក្រោម :

១- ទណ្ឌិតឈ្មោះ **ជួន សុប្បុត្រា** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១ ចុះថ្ងៃទី ១០.៥.៩៣ របស់តុលាការខេត្តក្រចេះ ។

២- ទណ្ឌិតឈ្មោះ **កែវ សុគីន** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ២ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ១៣ ចុះថ្ងៃទី ១៥.៧.៩៤ របស់តុលាការខេត្តក្រចេះ ។

៣- ទណ្ឌិតឈ្មោះ **គីម គាត** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧ ចុះថ្ងៃទី ២៧.៦.៨៧ របស់តុលាការខេត្តកណ្ដាល ។

៤- ទណ្ឌិតឈ្មោះ **សែម សែ** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាម អំណាចសាលក្រមលេខ ១១៨ ចុះថ្ងៃទី ១៧.៥.៩៤ របស់តុលាការខេត្តកណ្ដាល ។

៥- ទណ្ឌិតឈ្មោះ **សេខ លីន** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាម អំណាចសាលក្រមលេខ ១១៨ ចុះថ្ងៃទី ១៧.៥.៩៤ របស់តុលាការខេត្តកណ្ដាល ។

៦- ទណ្ឌិតឈ្មោះ **នូ ផន់** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ ចុះថ្ងៃទី ១៦.៧.៩៣ របស់តុលាការខេត្តកណ្ដាល ។

៧- ទណ្ឌិតឈ្មោះ **ឈុន ឆែខ** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២០១ ចុះថ្ងៃទី ១៨.៨.៩៤ របស់តុលាការខេត្តកណ្ដាល ។

៨- ទណ្ឌិតឈ្មោះ **ហ៊ុន ឆុន** ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាម អំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ១៧.១០.៨៤ របស់តុលាការខេត្តកណ្ដាល ។

៩– ទណ្ឌិតឈ្មោះ **ខុំ ចេន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី ២២.៨.៩២ របស់តុលាការខេត្ត កំពង់ធំ ។

១០– ទណ្ឌិតឈ្មោះ **ស្រេង ស៊ីថា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី ២២.៨.៩២ របស់តុលាការ ខេត្តកំពង់ធំ ។

១១– ទណ្ឌិតឈ្មោះ **ស៊ុន សយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៨ ចុះថ្ងៃទី ១០.៣.៩៤ របស់តុលាការ ខេត្តកណ្តាល ។

១២– ទណ្ឌិតឈ្មោះ **ស៊ុម ឡុង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៨ ចុះថ្ងៃទី ១០.៣.៩៤ របស់តុលាការ ខេត្តកណ្តាល ។

១៣– ទណ្ឌិតឈ្មោះ **ឡេ ម៉ាន់ក** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចក្រមលេខ ៣៧ ចុះថ្ងៃទី ២១.៨.៩៤ របស់តុលាការ ខេត្តកណ្តាល ។

១៤– ទណ្ឌិតឈ្មោះ **សុខ សុត** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨ ចុះថ្ងៃទី ២៧.៦.៨៧ របស់តុលាការ ខេត្តកណ្តាល ។

១៥– ទណ្ឌិតឈ្មោះ **ជឿន ថារី** ហៅក្រី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ កំណត់ ១២ឆ្នាំ តាមអំណាចសាលក្រមលេខ ៤ ចុះថ្ងៃទី ៦.៥.៩៣ របស់តុលា ការខេត្តកណ្តាល ។

១៦– ទណ្ឌិតឈ្មោះ **ឡាំ ឌីគូ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី ២៨.៨.៩២ របស់តុលាការខេត្ត កំពង់ធំ ។

១៧- ទណ្ឌិតឈ្មោះ **សោភ ឈាំ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ ចុះថ្ងៃទី ២៦.៧.៩១ របស់តុលាការខេត្តកំពង់ធំ ។

១៨- ទណ្ឌិតឈ្មោះ **ថោង ទុង** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះថ្ងៃទី ៣.៦.៩៣ របស់តុលាការខេត្តកំពង់ធំ ។

១៩- ទណ្ឌិតឈ្មោះ **សឿន ឡុយ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់៣ ឆ្នាំ តាម អំណាចសាលក្រមលេខ ៣២ ចុះថ្ងៃទី ២៩.៦.៩៤ របស់តុលាការខេត្តកំពង់ធំ ។

២០- ទណ្ឌិតឈ្មោះ **តាភ ម៉ិល** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ ចុះថ្ងៃទី ៣.៦.៩៣ របស់តុលាការខេត្តកំពង់ធំ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃឡាយហស្តលេខានេះតទៅ ។

មាត្រា ៦ : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និង ក្រសួងមហាផ្ទៃ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេចជាស្ថាពរ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II - ឱស្ថការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១៤ អនក្រ បក

ស្តីពីការបែងចែកខ្ទង់ចំណាយឥតគ្រោងទុក

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជ ក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ រកម ០១៩៦-១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ. ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ត្រូវបានផ្តល់ឥណទានបន្ថែមដោយដកពីជំពូក ៤១ (ចំណាយឥតគ្រោងទុក) នៃថវិការដ្ឋចំនួន ១០.០០០.០០០រ០០ ទៅជំពូក ១០របស់ក្រសួងអប់រំ យុវជន និងកីឡា សំរាប់មន្ទីរអប់រំ យុវជននិងកីឡា ខេត្តបន្ទាយមានជ័យ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មន្ទីរអប់រំ យុវជននិងកីឡាខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និងត្រា	**ហត្ថលេខា និងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៦១ អនក្រ តត

ស្តីពីការកែសំរួលឋានន្តរសក្តិ នាយទាហាន

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើតក្រសួងការពារជាតិ និងអគ្គសេនាធិការនៃកងទ័ពជាតិកម្ពុជា

– យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

សំរេច

មាត្រា ១ : ត្រូវបានគែសម្រួលឋានន្តរសក្តិ នាយទាហានថ្នាក់ **ឧត្តមសេនីយ៍ឯក** ក្នុងកងយោធពលខេមរភូមិន្ទ :

លោក **ចាន់ តារា** បច្ចុប្បន្នជាទីប្រឹក្សា មន្ទីរពេទ្យ ព្រះកេតុមាលា

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាកព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ដលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ដលេខា និងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៦២ អនក្រ.តត

ស្ដីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់លោកជំទាវ **ម៉ែន សំអន** តំណាងរាស្ត្រមណ្ឌលស្វាយរៀង

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « មាស» ស្ថាបនាជាតិជូនចំពោះសមាគមស៊ូម៉ាឆិនហៃ ដែលបានផ្តល់អំណោយដល់ប្រជារាស្ត្រខេត្តស្វាយរៀង ជាអណ្តូងស្នប់ចំនួន ៦០ អណ្តូង គិតជាប្រាក់ សរុប ៣១.២០០ ដុល្លាសហរដ្ឋអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្ត ស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខានិងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៦៣ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សម្រេច

មាត្រា ១ :ត្រូវបានប្រគល់មេដាយ « មាស » ស្ថាបនាជាតិជូនលោក **ខាំ លីម៉េង** និងភរិយា ជនជាតិ ខ្មែររស់នៅប្រទេសបារាំង ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនចំនួន ២៤.៥០០ ដុល្លាសហរដ្ឋអាមេរិក សំរាប់កសាងអាគារសិក្សា ០១ ខ្នង នៅក្នុងសាលាបឋមសិក្សា សូទិប ស្រុកជើងព្រៃខេត្តកំពង់ចាម ។

មាត្រា ២ :សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខានិងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៦៤ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ «មាស» ស្ថាបនាជាតិជូនលោក *TONY TANDIJONO* និង លោកស្រី *MICHIKO TANDIJONO* ប្រធានសណ្ឋាគារហូលីដេគ្រិប ដែលបានបរិច្ចាគ ថវិកាផ្ទាល់ខ្លួនចំនួន ១០.០០០ ដុល្លាសហរដ្ឋអាមេរិក សំរាប់ទិញសំភារៈបរិក្ខារពេទ្យបំពាក់អោយគិលានដ្ឋានឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាល ខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១ **នាយករដ្ឋមន្ត្រីទី ២**

ព្រះហស្តលេខានិងត្រា **ហត្ថលេខានិងត្រា**

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៦៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ«មាស»ស្ថាបនាជាតិជូនលោកស្រី **លឹម ស៊ុំណា** អនុប្រធានក្រុមហ៊ុនអង្គរអភិវឌ្ឍន៍ ដែលបានឧបត្ថម្ភថវិកាផ្ទាល់ខ្លួនចំនួន ២៣.០០០ ដុល្លាអាមេរិក ជួយដល់កុមារកំព្រាគៀនឃ្លាំង មណ្ឌលអភិវឌ្ឍន៍កោះថ្មី និងជីកអណ្តូងនៅខេត្តកំពង់ឆ្នាំង ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងនាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខានិងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ ៦៦ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយ « ប្រាក់ » ស្ថាបនាជាតិជូនឯកឧត្តម **ឆេង ចន** ទីប្រឹក្សាសម្តេច **ជា ស៊ីម** ដែលបានជួយរួមចំណែកកសាងអាគារសិក្សា០១ខ្នង នៅក្នុងវិទ្យាល័យតាខ្មៅ ខេត្តកណ្តាល អស់ទឹកប្រាក់ ៥.៧៩០ ដុល្លាសហរដ្ឋអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបាន លទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខានិងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ: ៦៧ អនក្រ.តត

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល
- តាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ

សំរេច

មាត្រា ១ : តែងតាំង :

១_អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ តានុវត្ត** ជានាយកខុទ្ទកាល័យ

២_លោក **សុក ឡៀន** ជាអធិការនៃអគ្គាធិការដ្ឋាន

៣_លោកស្រី **ស៊ីដា ឡាំបោនំ** ជាអធិការនៃអគ្គាធិការដ្ឋាន

៤_លោក **យុន ខ៊ែត** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស

៥_លោក **សេង គេង** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល ហិរញ្ញកិច្ច និង ផែនការ

៦_លោក **ឯក ដា** ជាប្រធាននាយកដ្ឋានរដ្ឋបាល និង បុគ្គលិក

៧_លោក **យឹម សំអឿន** ជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍

៨_លោក **ឈី ប្រុស** ជាប្រធាននាយកដ្ឋានផែនការនិងទំនាក់ទំនងសាធារណៈ

៩_លោក **សេង ណារ៉ុង** ជាប្រធាននាយកដ្ឋានបណ្តុះបណ្តាលនិងស្រាវជ្រាវ

១០_លោក **សោម សារិន** ជាប្រធាននាយកដ្ឋានផ្គត់ផ្គង់ និង ហិរញ្ញកិច្ច

១១_លោក **ពៅ យ៉ារ៉ា** ជាប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ

១២_លោក **ជា សំណាង** ជាប្រធាននាយកដ្ឋានថែទាំសុខភាពជនបទ

១៣_លោក **ម៉ៅ សារាយ** ជាប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ

១៤_លោក **អ៊ុំ សំ** ជាទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី

១៥_លោកស្រី **ឈាន់ស៊ី ចោយ** ជាទីប្រឹក្សាឯកឧត្តមរដ្ឋមន្ត្រី

១៦_លោក **ឃី ឃ្យុន** ជាទីប្រឹក្សាឯកឧត្តមរដ្ឋលេខាធិការ

១៧_លោក **ឈី ម៉ូ** ជាទីប្រឹក្សាឯកឧត្តមរដ្ឋលេខាធិការ

នៃក្រសួងអភិវឌ្ឍន៍ជនបទ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ និង សាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១
ព្រះហស្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខានិងត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ១៩៩៦

អនុក្រឹត្យ លេខ: ៦៨ អនក្រ.តត

ស្ដីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** , ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សំរេច [illegible]

មាត្រា ១ : ត្រូវបានតែងតាំងលោក **អ៊ុន ម៉ិយ** នាយកខុទ្ទកា[illegible]ទេស និង សហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សានៃស្ថានឯកអ[illegible]ណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ និង ជាជំនួ[illegible]បេសកកម្មអចិន្ត្រៃយ៍កម្ពុជាប្រចាំ *ESCAP* នៅ ទីក្រុងបាងកក [illegible]

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី[illegible]និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ [illegible]ខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងលោក **អ៊ុន ម៉ិយ** [illegible]អនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខានិងត្រា	**ហត្ថលេខានិងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

សេចក្តីសំរេច លេខ: ១២ សសរ

ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- ផ្អែកតាមការចាំបាច់

សំរេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាទេសរដ្ឋមន្ត្រីស្តីទី ទទួលបន្ទុកកិច្ចការវប្បធម៌ វិចិត្រសិល្បៈ រៀបចំដែនដី និងនគរូបនីយកម្ម ជំនួសឯកឧត្តមទេសរដ្ឋមន្ត្រី **វណ្ណ មូលីវណ្ណ** ចាប់ពីថ្ងៃទី ០៣ ខែ មេសា រហូតដល់ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ១៩៩៦ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និងឯកឧត្តម **គាត ឈន់** ត្រូវទទួលអនុវត្តសេចក្តីសំរេច ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខានិងត្រា	**ហត្ថលេខានិងត្រា**
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

ប្រកាស លេខ: ៣១២ ឧ.រ.ថ.ប្រ.ក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

* * *

ប្រការ ១ :អនុញ្ញាតអោយលោក **នៅ សុខា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥៧០០៧ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៨៨ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៣១ E_1 ផ្លូវ លេខ ១៤១ សង្កាត់អូរឫស្សីទី ២ ខណ្ឌ ៧ មករា បើកដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីនចំនួន ០២ គ្រឿងដែលមានកំលាំងសរុប ៣០០ KVA នៅក្នុងតំបន់បន្ទប់ភ្លើងលេខ ប.ត

២១០ ដែលស្ថិតនៅផ្លូវលេខ ១៦៣ សង្កាត់បឹងប្រលិតខណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **នៅ សុខា** ត្រូវអនុវត្តថ្លៃលក់ថាមពលអគ្គិសនីក្នុង ១ KWh តាមរូបមន្ត :

$$\frac{(\text{៣៥០៛} \times H) + (\text{៧០០៛} \times h)}{H + h}$$

ដោយស្រង់តួលេខខែមុនសំរាប់អនុវត្តខែបន្ទាប់ ។

H = ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់ ប.ត ២១១ ក្នុងខែមុន ។

h = ចំនួនម៉ោងដំណើរការម៉ាស៊ីនភ្លើងបំរុងខែមុន

៣៥០៛ = ថ្លៃលក់ថាមពលអគ្គិសនីដែលទទួលពី ក្រុមហ៊ុនអគ្គិសនីកម្ពុជា

៧០០៛ = ថ្លៃលក់ថាមពលអគ្គិសនី ដំណើរការដោយម៉ាស៊ីនបំរុង

ប្រការ ៣ : ប្រកាសនេះមានតំលៃអនុវត្តរហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់ បន្ទប់ភ្លើង ប.ត ២១០ នេះយកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់បញ្ញត្តិ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញ ដោយគ្មានសំណងឡើយ ។

* * *

?Á

ប្រកាស លេខៈ ៣១២ ឋ.ព.ប្រ.ក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **នៅ សុខា** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៥៧០០៧ ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ១៩៨៨ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ៣១ E_1 ផ្លូវលេខ ១៤១ សង្កាត់អូរឫស្សីទី ២ ខណ្ឌ ៧ មករា បើកដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីនចំនួន ០៣ គ្រឿងដែលមានកំលាំងសរុប ៤៥០ KVA នៅក្នុងតំបន់បន្ទប់ភ្លើងលេខ ប.ត.២១១ ដែលស្ថិតនៅផ្លូវលេខ ១៦៣ សង្កាត់អូរឫស្សីទី២ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **នៅ សុខា** ត្រូវអនុវត្តថ្លៃលក់ថាមពលអគ្គិសនីក្នុង ១ kWh តាមរូបមន្ត :

$$\frac{(\text{៣៥០៛} \times H) + (\text{៧០០៛} \times h)}{H + h}$$ ដោយស្រង់តួលេខខែមុនសំរាប់អនុវត្តខែបន្ទាប់ ។

H = ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់ ប.ត ២១០ ក្នុងខែមុន ។

h = ចំនួនម៉ោងដំណើរការម៉ាស៊ីនភ្លើងបំរុងខែមុន

៣៥០៛ = ថ្លៃលក់ថាមពលអគ្គិសនី ដែលទទួលពីក្រុមហ៊ុនអគ្គិសនីកម្ពុជា

៧០០៛ = ថ្លៃលក់ថាមពលអគ្គិសនីដំណើរការដោយម៉ាស៊ីនបំរុង

ប្រការ ៣ : ប្រកាសនេះមានតំលៃអនុវត្តរហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់បន្ទប់ភ្លើង ប.ត ២១១ នេះយកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់បញ្ញត្តិ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ: ៣១២ ឧ.ព.ប្រ.ក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ :អនុញ្ញាតអោយលោក **ទ៉ាន់ វ៉ាម៉ុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២៤០៥៦៣ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ១៩៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ៣៣២ E_2Z ផ្លូវលេខ ១២៨ សង្កាត់មិត្តភាព ខ័ណ្ឌ ៧មករា បើកដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីនចំនួន ០២ គ្រឿងដែលមានកំលាំងសរុប ២០០ kVA នៅ ក្នុងតំបន់បន្ទប់ភ្លើងលេខ ប.ត ១៩២ ដែលស្ថិតនៅផ្លូវលេខ ១៥៩ សង្កាត់មិត្តភាព ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ទ៉ាន់ វ៉ាម៉ុន** ត្រូវអនុវត្តថ្លៃលក់ថាមពលអគ្គិសនីក្នុង១ kWh តាមរូបមន្ត :

$$\frac{(៣៥០៛ \times H) + (៧០០៛ \times h)}{H + h}$$ ដោយស្រង់តួលេខខែមុនសំរាប់អនុវត្តខែបន្ទាប់ ។

H = ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់ ប.ត ១៩២ ក្នុង ខែមុន ។

h = ចំនួនម៉ោងដំណើរការម៉ាស៊ីនភ្លើងបំរុងខែមុន ៣៥០៛ = ថ្លៃលក់ថាមពលអគ្គិសនីដែលទទួលពីក្រុមហ៊ុនអគ្គិសនីកម្ពុជា ៧០០៛ = ថ្លៃលក់ថាមពល

អគ្គិសនីដំណើរការដោយម៉ាស៊ីនបំរុង ។

ប្រការ ៣ : ប្រកាសនេះមានតំលៃអនុវត្តរហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់បន្ទប់ភ្លើង ប.ត ១៩២ នេះយកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់បញ្ញត្តិ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៣១២ ស.ព.ប្រ.ក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ស៊ើ ផល្លា** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣០៣០៧ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ១៩៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៧៧អឺ១ ផ្លូវលេខ១៣៩ សង្កាត់ទួលស្វាយព្រៃទី២ ខ័ណ្ឌចំការមន បើកដំណើរការរោង ម៉ាស៊ីនបំរុងផលិតថាមពល អគ្គិសនីដោយប្រើម៉ាស៊ីនចំនួន.០១គ្រឿង ដែលមានកំលាំង សរុប,៦០ kvA នៅក្នុងតំបន់បន្ទប់ភ្លើងលេខ ប.ត.៤០៩ ដែលស្ថិតនៅផ្លូវលេខ៣១៨ សង្កាត់ទួលស្វាយព្រៃទី២ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ។

ប្រការ ២ : លោក **ស៊ើ ផល្លា** ត្រូវអនុវត្តន៍ថ្លៃលក់ថាមពលអគ្គិសនីក្នុង 1kwh តាមរូបមន្ត : $\frac{(350៛\times H) + (700៛\times h)}{H + h}$ ដោយស្រង់តួលេខខែមុនសំរាប់អនុវត្តន៍ខែបន្ទាប់ ។

H = ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់បត៤០៩ក្នុងខែមុន

h= ចំនួនម៉ោងដំណើរការម៉ាស៊ីនភ្លើងបំរុងក្នុងខែមុន

350៛ – ថ្លៃលក់ថាមពលអគ្គិសនីដែលទទួលពីក្រុមហ៊ុនអគ្គិសនីកម្ពុជា ។

700៛ – ថ្លៃ លក់ថាមពលអគ្គិសនីដំណើរការដោយម៉ាស៊ីនបំរុង ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃអនុវត្តរហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់បន្ទប់ភ្លើង ប.ត៤០៩នេះយកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់បញ្ញត្តិ បង្ករអោយមានការប៉ះពាល់ដល់បរិស្ថានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ : ៣១២ ម.ព.ប្រ.ក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ហេង សាន** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ២៣៣២៨៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ១៩៩៣ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៥៦ ផ្លូវលេខ៦៣ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ បើកដំណើរការរោងម៉ាស៊ីន បំរុងផលិត ថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីន ចំនួន.០១គ្រឿងដែលមានកំលាំងសរុប ១00KVA នៅក្នុងតំបន់បន្ទប់ភ្លើងលេខប.ត.៣៥៨ ដែលស្ថិតនៅផ្លូវលេខ៣១៨ សង្កាត់បឹងរាំង ខ័ណ្ឌដូនពេញ ។

ប្រការ២ :លោក **ហេង សាន** ត្រូវអនុវត្តន៍លក់ថាមពលអគ្គិសនីក្នុង 1kwh តាមរូបមន្ត :

$$\frac{(350៛ \times H) + (700៛ \times h)}{H + h}$$

ដោយស្រង់តួលេខខែមុន សំរាប់អនុវត្តន៍ ខែបន្ទាប់ ។

H= ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់បត៣៥៨ ក្នុងខែមុន

h= ចំនួនម៉ោងដំណើរការម៉ាស៊ីនភ្លើងបំរុងក្នុងខែមុន

350៛ –ថ្លៃលក់ថាមពលអគ្គិសនី ដែលទទួលពីក្រុមហ៊ុនអគ្គិសនីកម្ពុជា ។

700៛ –ថ្លៃលក់ថាមពលអគ្គិសនីដំណើរការដោយម៉ាស៊ីនបំរុង ។

ប្រការ ៣ :ប្រកាសនេះមានតម្លៃអនុវត្តរហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់បន្ទប់ភ្លើងប.ត៣៥៨នេះយកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់បញ្ញត្តិ ឬបង្កអោយមាន ការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៣១២ ម.ព.ប្រ.ក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ :អនុញ្ញាតអោយលោក **ហេង តៃ** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់ប័ណ្ណគ្រួសារ លេខ ២១៧ សេ ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ១៩៨៨ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ៦១ ផ្លូវលេខ៤០២ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន បើកដំណើរការរោងម៉ាស៊ីនបំរុង ផលិតថាមពលអគ្គិសនី ដោយប្រើម៉ាស៊ីនចំនួន.០២គ្រឿង ដែលមានកំលាំងសរុប

២៤០kvA នៅក្នុងតំបន់ បន្ទប់ភ្លើងលេខប.ត២៨៧ ដែលស្ថិតនៅផ្លូវលេខ ១៩៩ សង្កាត់ ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ :លោក **ហេង តៃ** ត្រូវអនុវត្តន៍លក់ថាមពលអគ្គិសនីក្នុង 1kwh តាមរូបមន្ត :

$$\frac{(350៛\times H) + (700៛\times h)}{H + h}$$

ដោយស្រង់តួលេខខែមុនសំរាប់អនុវត្តន៍ ខែ បន្ទាប់ ។

H= ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់ ប.ត ២៨៧ ក្នុងខែមុន

h= ចំនួនម៉ោងដំណើរការម៉ាស៊ីនភ្លើងបំរុងក្នុងខែមុន 350៛ –ថ្លៃលក់ថាមពលអគ្គិសនី ដែលទទួលពីក្រុមហ៊ុនអគ្គិសនីកម្ពុជា 700៛–ថ្លៃលក់ថាមពលអគ្គិសនីដំណើរការដោយម៉ាស៊ីនបំរុង ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃអនុវត្តរហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់បន្ទប់ភ្លើង ប.ត២៨៧ នេះយកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់បញ្ញត្តិ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៣១២ ឧ.ព.ប្រ.ក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១: អនុញ្ញាតអោយលោក **អ៊ុន សុផល** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០២១៦៩៧ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៨៤ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ PGE 0 ផ្លូវជ្រុនយូហាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន បើកដំណើរការរោងម៉ាស៊ីនបំរុង ផលិតថាមពលអគ្គិសនីដោយប្រើម៉ាស៊ីនចំនួន.០២គ្រឿង ដែលមានកំលាំងសរុប.៥៧០ kVA នៅក្នុងតំបន់បន្ទប់ភ្លើងលេខ ប.ត.៣៧៥ ដែលស្ថិតនៅផ្លូវលេខ ៣១០ សង្កាត់បឹងកេងកងទី ១ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ប្រការ ២: លោក **អ៊ុន សុផល** ត្រូវអនុវត្តន៍ថ្លៃលក់ថាមពលអគ្គិសនីក្នុង ១ kVA តាមរូបមន្ត:

$$\frac{(350៛\times H) + (700៛\times h)}{H + h}$$

ដោយស្រង់តួលេខខែមុនសំរាប់អនុវត្តន៍ខែបន្ទាប់ ។

H= ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់ ប.ត ៣៧៥ ក្នុងខែមុន

h= ចំនួនម៉ោងដំណើរការម៉ាស៊ីនភ្លើងបំរុងក្នុងខែមុន

350៛–ថ្លៃលក់ថាមពល អគ្គិសនីដែលទទួលពីក្រុមហ៊ុនអគ្គិសនីកម្ពុជា

700៛–ថ្លៃលក់ថាមពលអគ្គិសនីដំណើរការដោយម៉ាស៊ីនបំរុង ។

ប្រការ ៣ :ប្រកាសនេះមានតម្លៃអនុវត្តរហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់បន្ទប់ភ្លើងប.ត៣៧៥នេះយកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់បញ្ញត្តិ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៣១២ ឧ.ព.ប្រ.ក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ឡេង គីមហួយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណ លេខ ន ២៩៧៧ ប.ស ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៦ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៧៩ ផ្លូវជាតិ លេខ១ សង្កាត់ច្បារអំពៅទី ១ ខ័ណ្ឌមានជ័យ បើកដំណើរការ រោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនីដោយប្រើម៉ាស៊ីនចំនួន .០១គ្រឿង ដែលមានកំលាំងសរុប ៣០០ kVA នៅក្នុងតំបន់ភ្លើង លេខ ប.ត.២០៦ ដែលស្ថិតនៅផ្លូវលេខ២១៣ សង្កាត់វាលវង់ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ។

ប្រការ ២: លោក **ឡេង គីមហួយ** ត្រូវអនុវត្តន៍ថ្លៃលក់ថាមពលអគ្គិសនីក្នុង ១ kVA តាមរូបមន្ត:

$$\frac{(350៛\times H) + (700៛\times h)}{H + h}$$

ដោយស្រង់តួលេខខែមុនសំរាប់ អនុវត្តន៍ខែបន្ទាប់ ។

H= ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់ ប.ត២០៦ក្នុងខែមុន

h= ចំនួនម៉ោងដំណើរការម៉ាស៊ីនភ្លើងបំរុងក្នុងខែមុន

350៛–ថ្លៃលក់ថាមពលអគ្គិសនីដែលទទួលពីក្រុមហ៊ុនអគ្គិសនីកម្ពុជា

700៛ថ្លៃលក់ថាមពល អគ្គិសនីដំណើរការដោយម៉ាស៊ីនបំរុង ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃអនុវត្តរហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់បន្ទប់ភ្លើងប.ត ២០៦ នេះយកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់បញ្ញត្តិ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ:៣១២ ថ.ព.ប្រ.ក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១: អនុញ្ញាតអោយលោក **ជាវ តាយ** ជនជាតិខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ខ ០៩៣៥០៩ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥៦៨ក១ ផ្លូវជាតិលេខ១ សង្កាត់ច្បារអំពៅទី ២ ខ័ណ្ឌ មានជ័យ បើកដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនីដោយប្រើម៉ាស៊ីនចំនួន.០១ គ្រឿង ដែលមានកំលាំងសរុប ១២០kVA នៅបន្ទប់ក្នុងតំបន់ភ្លើងលេខ ប.ត.២៨៨ ដែលស្ថិតនៅវិថីសម្តេចព្រះសីហនុ ខ័ណ្ឌ៧មករា រាជធានីភ្នំពេញ ។

ប្រការ២: លោក ជាវ តាយ ត្រូវអនុវត្តន៍ថ្លៃលក់ថាមពលអគ្គិសនីក្នុង១ kwh តាមរូបមន្ត:

$$\frac{(350៛\times H) + (700៛\times h)}{H + h}$$

ដោយស្រង់តួលេខខែមុនសំរាប់អនុវត្តន៍ខែបន្ទាប់ ។

H= ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់ ប.ត ២៨៨ ក្នុងខែមុន

h= ចំនួនម៉ោងដែលដំណើរការដោយម៉ាស៊ីនភ្លើងបំរុង

350៛ –ថ្លៃលក់ថាមពលអគ្គិសនីដែលទទួលពីក្រុមហ៊ុនអគ្គិសនីកម្ពុជា

700៛ –ថ្លៃលក់ថាមពលអគ្គិសនីដំណើរការដោយម៉ាស៊ីនបំរុង ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃអនុវត្តរហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់បន្ទប់ភ្លើង ប.ត ២៨៨ នេះយកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់បញ្ញត្តិ ឬបង្កអោយមាន ការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ : ៣១២ ម.ព.ប្រ.ក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រការ ១ : អនុញ្ញាតអោយលោក **ហែម ចន្ទសឿន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៤៦៧៩៩ ចុះថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ១៩៨៨ អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ ១០ ផ្លូវលេខ៣៦៦ សង្កាត់ផ្សារដេប៉ូទី ១ ខ័ណ្ឌ ទួលគោក បើកដំណើរការរោងម៉ាស៊ីនបំរុងផលិតថាមពលអគ្គិសនីដោយប្រើម៉ាស៊ីន ចំនួន.០២ គ្រឿង ដែលមានកំលាំងសរុប ៣០០ kVh នៅក្នុងតំបន់ភ្លើងលេខ ប.ត.១៦១ ដែលស្ថិតនៅផ្លូវលេខ១៨២-២២៩ សង្កាត់ផ្សារដេប៉ូទី១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២: លោក **ហែម ចន្ទសឿន** ត្រូវអនុវត្តនិថ្លៃលក់ថាមពលអគ្គិសនីក្នុង kVA តាមរូបមន្ត:

$$\frac{(350\text{៛} \times H) + (700\text{៛} \times h)}{H + h}$$

ដោយស្រង់តួលេខខែមុនសំរាប់អនុវត្តន៍ខែបន្ទាប់ ។

H= ចំនួនម៉ោងដែលក្រុមហ៊ុនអគ្គិសនីបានផ្គត់ផ្គង់ថាមពលអោយតំបន់បត ១៦១ ក្នុងខែមុន

h= ចំនួនម៉ោងដំណើរការដោយម៉ាស៊ីនភ្លើងបំរុងក្នុងខែមុន

350៛ –ថ្លៃលក់ថាមពល អគ្គិសនីដែលទទួលពីក្រុមហ៊ុនអគ្គិសនីកម្ពុជា ។

700៛ –ថ្លៃលក់ថាមពលអគ្គិសនី ដំណើរការដោយម៉ាស៊ីនបំរុង ។

ប្រការ៣ : ប្រកាសនេះមានតម្លៃអនុវត្តរហូតដល់ពេលក្រុមហ៊ុនអគ្គិសនីកម្ពុជាផ្ទេរតំបន់បន្ទប់ភ្លើង ប.ត ១៦១ នេះយកមកគ្រប់គ្រងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់បញ្ញត្តិ

ឬបង្កអោយមាន ការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

អ៊ុត ឆ្រាំង

* * *

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

ភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រកាសលេខ : ៣២៧ អយក. ប្រក

ស្តីពីការប្តូរឈ្មោះអនុវិទ្យាល័យព្រែកអំបិលទៅជា" អនុវិទ្យាល័យ

ហ៊ុន សែន — ព្រែកអំបិល" ក្នុងស្រុកស្អាង ខេត្តកណ្តាល

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះ[illegible]ាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែង [illegible] ដ្ឋាភិបាលកម្ពុជា
- [illegible] ញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាស អោ[illegible] ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បា[illegible] ញក្រឹត្យ– ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំ[illegible]ណៈទូទៅ
- យោងលិខិតរបស់គណៈទ្រទ្រង់អនុវិទ្យាល័យព្រែកអំបិលលេខ ០១–៩៦ អនុវិ. ព. ប ចុះថ្ងៃទី ១៧ មីនា១៩៩៥ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកណ្តាល
- តាមសំណើរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សម្រេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះអនុវិទ្យាល័យព្រែកអំបិលបច្ចុប្បន្នទៅជា«អនុវិទ្យាល័យ **ហ៊ុន សែន**– ព្រែកអំបិល » ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

ប្រការ២ បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជន និង កីឡា–ប្រធានមន្ទីរអប់រំយុវជន និង កីឡាខេត្តកណ្តាល និង នាយកអនុវិទ្យាល័យ ហ៊ុន សែន– ព្រែកអំបិល មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និង ត្រា
តា សាមាន

* * *

ភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រកាសលេខ: ៣២៨ អយក.ប្រក

ស្តីពីការបើក អនុវិទ្យាល័យ ហ៊ុន សែន–គ្រប់ ក្នុងស្រុកបាធាយ

ខេត្ត កំពង់ចាម

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ។
- បានឃើញក្រឹត្យ–ច្បាប់លេខ៣០ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃ ០២ ខែ មេសា ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត ១ –កំរិត ២
- យោងលិខិតលេខ ២១៦ អយក.បផ ចុះថ្ងៃទី ២០ កក្កដា ១៩៩៥ របស់ប្រធានការិយាល័យអប់រំ យុវជន និង កីឡាស្រុកបាធាយ ដោយមានការឯកភាពពីប្រធានមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាលខេត្តកំពង់ចាម
- តាមសំណើររបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយមន្ទីរអប់រំយុវជន និង កីឡាខេត្តកំពង់ចាមបើក អនុវិទ្យាល័យ ដែលមាន ឈ្មោះថា" អនុវិទ្យាល័យ **ហ៊ុន សែន – ត្រប់**" នៅក្នុងស្រុកបាធាយខេត្តកំពង់ចាម ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ នេះតទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមចាំបាច់ព្រមទាំងបុគ្គលិក ផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក–នាយករងនៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់ នាយក-នាយករង នៃអនុវិទ្យាល័យ ។

ប្រការ ៤ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជននិងកីឡា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តកំពង់ចាម នាយកអនុវិទ្យាល័យ **ហ៊ុន សែន** ត្រប់ មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គា សាម៉ាន

ភ្នំពេញ, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៦

ប្រកាសលេខ: ៣២៩ អយក.ប្រក

ស្តីពីការប្តូរឈ្មោះវិទ្យាល័យ តាកែវ ទៅជា វិទ្យាល័យ

"ជា ស៊ីម– តាកែវ" ក្នុងខេត្តតាកែវ

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤

– បានឃើញក្រឹត្យ–ច្បាប់លេខ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំទូទៅ

– យោងលិខិតរបស់សមាគមមាតាបិតាសិស្សទ្រទ្រង់ វិទ្យាល័យ តាកែវ ចុះថ្ងៃទី ២៧ កុម្ភៈ ១៩៩៦ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំយុវជន និង កីឡា និង អភិបាលខេត្តតាកែវ

– តាមយោបល់ឯកភាពរបស់ សម្តេច **ជា ស៊ីម**

សំរេច

ប្រការ ១ : អនុញ្ញាតអោយប្តូរឈ្មោះវិទ្យាល័យតាកែវ បច្ចុប្បន្នទៅជា "វិទ្យាល័យ **ជា ស៊ីម**–តាកែវ" ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ តទៅ ។

ប្រការ ២: បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋានផែនការ និង ហិរញ្ញកិច្ច នៃក្រសួងអប់រំយុវជននិងកីឡា

ប្រធានមន្ទីរ អប់រំយុវជននិងកីឡា ខេត្តតាកែវ និង នាយកវិទ្យាល័យ ជា ស៊ីម តាកែវ មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

គា សាហាន

* * *

ភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៦

ប្រកាសលេខ: ៣៣០ អយក. ប្រ.ក

ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា ចំនួ សារុន ស្ទោងខ្ទិ

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០–៧–១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រ.ច ចុះថ្ងៃទី ២០–១១–៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានពិនិត្យលិខិតស្នើសុំរបស់មន្ទីរអប់រំ យុវជន និង កីឡាខេត្តតាកែវលេខ ១៥៦៩ អយកត. បឋម ចុះថ្ងៃទី ២២–៣–៩៦ ដោយមានចំណារឯកភាពរបស់អភិបាលខេត្ត រងទី ២ លេខ ៤៧៣ លខ. បជ ចុះថ្ងៃទី ២២–៣–៩៦
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា

សំរេច

ប្រការ ១ :អនុញ្ញាតអោយមន្ទីរអប់រំយុវជន និង កីឡា ខេត្តតាកែវ ប្តូរឈ្មោះសាលាបឋមសិក្សា **ច័ន្ទ សារុន** ស្មៅខ្ញី នៅឃុំត្រពាំងសាប ស្រុកបាទី ខេត្តតាកែវ មកជាសាលាបឋមសិក្សា **ហាំង ថោ** ស្មៅខ្ញី វិញ ចាប់ពីឆ្នាំសិក្សា ១៩៩៥–៩៦ នេះតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : ប្រធានមន្ទីរ ក្រសួងអប់រំ យុវជន និង កីឡា ប្រធាននាយកដ្ឋានចាត់តាំង ប្រធាននាយកដ្ឋាន ផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធានមន្ទីរអប់រំ យុវជន និង កីឡាខេត្តតាកែវ ប្រធានការិយាល័យអប់រំយុវជន និង កីឡាស្រុកបាទី នាយកសាលាបឋមសិក្សា **ហាំង ថោ** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

តា សាហាន

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៧៥០ រៀល